**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

**ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា**

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# សេចក្តីសម្រេចកែសម្រួលលើកទី២

## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ១៣៦ ឯអ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦ សម្រាប់លោក ម៉ែន គន្ធា ធ្វើសេវាកម្មអគ្គិសនី នៅទីប្រជុំជនផ្សារតាឡាត់ ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ សម្រាប់ការបង្កើនអាណត្តិអាជ្ញាប័ណ្ណ និងការពង្រីកតំបន់ចែកចាយ

# DECISION ON THE SECOND REVISION

## OF THE CONSOLIDATED LICENSE DOCUMENT No.136 LD DATED JUNE 28, 2006 OF MR. MEN KUNTHEA FOR PROVIDING ELECTRIC POWER SERVICES AT PHSAR TALAT TOWN, KHUM O, PHNOM SRUOCH DISTRICT, KAMPONG SPEU PROVINCE FOR INCREASING TERM OF LICENSE AND EXTENDING DISTRIBUTION AREA

ថ្ងៃទី... ខែ... ឆ្នាំ២០០៩

..., 2009

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**NATION RELIGION KING**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

លេខ : -០៩-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាប័ណ្ណលេខ ១៣៦ ឯអ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦
# សម្រាប់លោក ម៉ែន គន្ធា

## DECISION ON THE SECOND REVISION
## OF THE CONSOLIDATED LICENSE DOCUMENT No.136 LD
## DATED JUNE 28, 2006 FOR MR. MEN KUNTHEA

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 02 February 2001.
- យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ១៣៦ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក ម៉ែន គន្ធា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦
- Refer to the Consolidated License No. 136 LD issued to Mr. Men Kunthea by Electricity Authority of Cambodia on June 28, 2006.
- យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនី និងបង្កើនអាណត្តិអាជ្ញាប័ណ្ណរបស់លោក ម៉ែន គន្ធា ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩
- In accordance with the requested letter for extending distribution area and increasing term of Mr. Men Kunthea dated April 7, 2009.
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០០៩
- In accordance with the consultation with concerned parties and public, made from ...., 2009 to ..., 2009.
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៩
- In accordance with the decision of Electricity Authority of Cambodia's Session No. ..., dated ..., 2009.

# សម្រេច
# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណរួមលេខ ១៣៦ ឯអ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦ ដែលបានផ្តល់ជូនលោក **ម៉ែន គន្ធា** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារតាឡាត់ ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដូចខាងក្រោម: | **Article 1**<br>To revise the consolidated license document No. 136 LD dated June 28, 2006 issued to Mr. **MEN KUNTHEA** (herein after referred to as **"Licensee"**) for providing the electric power services at Phsar Talat Town, Khum O, Phnom Sruoch District, Kampong Speu Province as follow: |
| -ដោយអ្នកកាន់អាជ្ញាប័ណ្ណ បានកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានមួយចំនួនធំ ស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវធ្វើការកែលម្អជាបន្តទៀត អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចបង្កើនអាណត្តិអាជ្ញាប័ណ្ណពី ០២(ពីរ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ។ អាណត្តិរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល ០៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៨ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។<br>-អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ (មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ កែសម្រួលថ្មី) ។ | - As the Licensee has improved big part of facilities in accordance with Electric Power Technical Standards of the Kingdom of Cambodia and has to improve further in coming years, EAC decides to increase term of license from 02 (two) to 05 (five) years. The term of the license shall be 05 (five) years from June 28, 2008 and may be renewed for further periods unless revoked earlier in accordance with the conditions of license.<br>- To provide the right to licensee to add more distribution areas to its existing areas of supply the electric power service (As shown in the attached map in new revised schedule 1). |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ១៣៦ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 1 of the license document No.136 LD is replaced by the new revised schedule 1 attached herewith. |
| **ប្រការ៣**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ១៣៦ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article3**<br>The other contents and conditions of the license document No. 136 LD shall remain unaltered and in force |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១៣៦ ឯអ ។ | **Article 4**<br>This decision and the attached Schedule are the part of license document No. 136 LD |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |

| | |
|---|---|
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ១៣៦ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ១៣៦ ឯអ ដែលតម្កល់ទុក មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 136 LD has been deposited in order that the deposited license document No. 136 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០០៩

Phnom Penh, ..., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី ... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC Nº ... DATED ..., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាត្តឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី នៅទីប្រជុំជនផ្សារតាឡាត់ ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ | 1. The authorizes distribution Areas, where the licensee have the right to provide the electricity distribution and supply services are Talat Town, Khum O, Phnom Sruoch District, Kampong Speu Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយ " ផែនទីកំណត់ព្រំប្រទល់ មានបង្ហាញក្នុងផែនទីលេខ 136LD-Map-Men Kunthea-Revision-2-2009 " ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution areas is determined by "the boundary maps No. 136 LD-Map-Men Kunthea-Revision-2-2009" attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងស្នើសុំពង្រីកឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយ ភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if the licensee intends to request the extension or the additional distribution areas then licensee shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |